**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសភាពាណិជ្ជកម្មខេត្តព្រះវិហារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦៩៥ / ០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបបនិងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- តាមសំណើរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១ .**

បង្កើតសភាពាណិជ្ជកម្មមួយសំរាប់ខេត្តព្រះវិហារ ហៅថាសភាពាណិជ្ជកម្មខេត្តព្រះវិហារ ព្រំដែនមណ្ឌលសភាពាណិជ្ជកម្មខេត្តព្រះវិហារ គឺកំណត់តាមព្រំដែនខេត្តព្រះវិហារ ។

**មាត្រា ២ .**

សភាពាណិជ្ជកម្មខេត្តព្រះវិហារ មានសមាជិកជ្រើសតាំងចំនួនដប់ប្រាំរូប (១៥រូប) ដែលជ្រើសរើសតាមការបោះឆ្នោត ។ សភាពាណិជ្ជកម្មខេត្តព្រះវិហារ អាចបង្កើតគណៈកម្មការផ្សេងៗតាមការចាំបាច់ដើម្បីអភិវឌ្ឍប្រភេទអាជីវកម្មនីមួយៗ ។

**មាត្រា ៣ .-**

តាមសំណើរបស់ប្រធានសភាពាណិជ្ជកម្មខេត្តព្រះវិហារ ក្រសួងពាណិជ្ជកម្មត្រូវកំណត់តាមប្រកាសនូវសមាជិកទីប្រឹក្សាស្របតាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ០៥ នៃច្បាប់ ស្តីពី សភាពាណិជ្ជកម្ម ។

**មាត្រា ៤ .**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីរដ្ឋលេខាធិការក្រសួងពាណិជ្ជ អភិបាលខេត្តព្រះវិហារ និងប្រធានសភាពាណិជ្ជកម្មខេត្តព្រះវិហារត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០៤

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេច នាយករដ្ឋមន្ត្រី សូមឡាយហត្ថលេខា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

**ចម ប្រសិទ្ធ**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ដូចមាត្រា ៥
- សាលាខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ